# ខ្លឹមសារសង្ខេបសាលក្រមតុលាការជាន់ខ្ពស់ហុងកុង

Criminal Appeal No. 269 of 2006, HKSAR and LI SHOU WEN, 13 February

**<u>ពាក្យគន្លឹះ៖</u>** បទឧក្រិដ្ឋមានការចាត់តាំង, គោលការណ៍នៃការដាក់ទោស

## ១. ប្រវត្តិនីតិវិធី

ជនជាតិចិនដីគោកចំនួន៣រូប បានមកទីក្រុងហុងកុង រួមគ្នាឆបោកស្ត្រីហុងកុងម្នាក់ តាមរយៈការលក់គ្រឿងបន្លាស់កុំព្យូទ័រ (តាមពិតគ្រឿងវិទ្យុ) ដោយប្រាប់ពីផលិតផលដែលពួកគេចង់លក់ជូន។ អ្នកទិញអាចលក់ចេញបានប្រាក់ចំណេញ។ ម្នាក់ក្នុងក្រុម (អ្នកទី១) ដើរតួជាអ្នកទាក់ទងរកអ្នកទិញ និង អ្នកលក់ (អ្នកទីពី) (មួយគ្រឿង២០០ដុល្លាហុងកុង) ហើយបានប្រាប់ស្ត្រីជាអ្នកទិញ យកទៅលក់ឲ្យមនុស្សម្នាក់ផ្សេង (អ្នកទីបី) (ក្នុងមួយគ្រឿង៣០០ដុល្លាហុងកុង) ដើម្បីបានចំណេញ។ អ្នកទី១ បានឯកភាពរកស៊ីជាមួយស្រីនោះ។ ស្ត្រីអ្នកទិញ បានប្រគល់លុយមួយចំណែកទៅឲ្យអ្នកទី២ ព្រមទាំងទទួល និងប្រគល់វត្ថុទៅឲ្យអ្នកទីបី ដើម្បីលក់យកតម្លៃចំណេញ។ ក្រោយមក អ្នកទាំងបី បានបាត់ខ្លួន។ ទឹកប្រាក់ដែលគាត់ខាតបង់ប្រហែល ២០០,០០០ ដុល្លាហុងកុង។ មួយរយៈក្រោយមក ស្ត្រីអ្នកទិញ បានជួបដោយចៃដន្យ ស្គាល់អត្តសញ្ញាណ ជនល្មើសម្នាក់ (អ្នកទី១) ក៏ប្តឹងនគរបាលឲ្យឃាត់ខ្លួន (កថា.៥)។

នីតិវិធីចោទប្រកាន់ ត្រូវបានចាប់ផ្តើម។ ជនល្មើស ត្រូវបានចោទប្រកាន់លើបទល្មើសចំនួន៤ (កថា. ៣)។ គាត់បានប្តឹងមកតុលាការជាន់ខ្ពស់ដើម្បីសុំសម្រាលទោស។ រដ្ឋអាជ្ញា បានប្តឹងស្នើបន្ថែមទោស ដោយសារបទល្មើស មានចរិតអង្គការចាត់តាំង(កថា. ៧)។

## ២. វិធានអនុវត្ត

ដើម្បីបង្កើនទោសបាន លុះត្រាការប្រព្រឹត្ត ត្រូវចូលក្នុងស្ថានទម្ងន់ណាមួយ ដូចជាការប្រព្រឹត្តដោយមានអង្គការចាត់តាំង។ ទោះបីជាយ៉ាងនេះក្តី ការដាក់ទោស ក៏ត្រូវតែពិចារណាផងដែរនូវស្ថានសម្រាល។ ចៅក្រមគិតតាមរូបមន្ត៖ ១. ចំនួនទោសចាប់ផ្តើមដ៏សមស្រប (២ឆ្នាំសម្រាប់បទចោទនីមួយៗ) ក្នុងករណីជនជាប់ចោទបានសារភាព (guilty plea) ទី២. ដកមួយភាគបីជាការបន្ថយទោសនៃបទចោទនីមួយៗ (សល់១៦ខែ) ប្រសិនបើមានស្ថានសម្រាល ឬ ទី៣. ទោសសរុប២៤ខែ (គ្មានស្ថានសម្រាល) និងទី៤. បន្ថែម៥០ភាគរយនៃទោសដំបូង (ក្រោយមាន guilty plea) ប្រសិនបើមានស្ថានទម្ងន់។

## ៣. សម្អាងហេតុ និងខ្លឹមសារសម្រេច

ថៅក្រម បានរកឃើញថា អ្នកប្ដឹងជាសមាជិកនៃក្រុមចាត់តាំង មានផែនការរឹងមាំ ប្រើល្បិចជាធ្នាក់ទាក់ទងជនរងគ្រោះនាំឲ្យមានការខាតបង់ថវិកា (កថាខ័ណ្ឌទី១៥)។

ក្នុងរឿងនេះ ទោសចាប់ផ្ដើមគឺ៣ឆ្នាំ ក៏ប៉ុន្តែដោយសារជនជាប់ចោទបានសារភាព (guilty pleas, កថាខ័ណ្ឌទី៨) ថៅក្រមចាប់គិតទោសពី២ឆ្នាំទៅ។ បទចោទចំនួនមួយ មានស្ថានទម្ងន់ ត្រូវទទួលទោស៣ឆ្នាំ (២៤ខែ បូកនិង៥០ភាគរយគឺ១២ខែ) បូកនិងទោស៦ខែ សម្រាប់បទចោទនីមួយៗចំនួន៣ទៀត (១៨ខែ)។ ដូចនេះទោសសរុបទាំងបួនបទចោទ គឺ៥៤ខែ (បួនឆ្នាំកន្លះ)។

ថៅក្រម ដែលសម្រេចដាក់ទោសជនជាប់ចោទ៤ឆ្នាំកន្លះក្នុងពន្ធនាគារ ជាការសមស្របហើយ។ យើងក៏មិនឯកភាព តាមសំណើរបស់រដ្ឋអាជ្ញាឲ្យបន្ថែមទោសដែរ។ យើងសម្រេចបដិសេធនូវបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ (កថា. ២១)។

## ៤. ប្រភពឯកសារ

សម្រាប់អត្ថបទនៃសេចក្ដីសម្រេចទាំងស្រុង សូមចូលទៅកាន់គេហទំព័រ៖

http://www.measboralaws.com/images/pdf/verdict/bc05beef5785d4226dac5f9ac5a2f4aa.pdf